# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យា
## ស្តីពី
## ការកែតម្រូវកិច្ចសន្យាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០
## រវាង
## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## និង
## ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថឺរ

- យោងកិច្ចសន្យាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថឺរ ស្តីពីការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម និងដាំកៅស៊ូ ដែលមានទីតាំងស្ថិតនៅស្រុកសំបូរ ខេត្តក្រចេះ
- អនុលោមតាមប្រការ១៨ នៃកិច្ចសន្យាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថឺរ ស្តីពីការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម និងដាំកៅស៊ូ ដែលមានទីតាំងស្ថិតនៅស្រុកសំបូរ ខេត្តក្រចេះ
- យោងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតថឺរ ចំនួន ៣១ច្បាប់
- យោងលិខិតលេខ១១៧ សជណ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ ដូចខាងក្រោម៖

**ប្រការ១** : ត្រូវបានកែសម្រួលចំណុច១.១ ក្នុងប្រការ១ នៃកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ មកជាប្រការ១ថ្មី ទៅជាកម្មវត្ថុនៃកិច្ចសន្យានេះ ភាគី "ក" យល់ព្រមផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានផ្ទៃក្រឡាសរុបចំនួន ៧ ៧៦៣,៨៩ (ប្រាំពីរពាន់ប្រាំពីររយហុកសិបបីក្បៀសប៉ែតសិបប្រាំបួន) ហិកតា ជាផ្ទៃដីត្រូវបានចុះបញ្ជីដីរដ្ឋរួចរាល់មានទីតាំងស្ថិតនៅស្រុកសំបូរ

ខេត្តក្រចេះ ជូនភាគី "ខ" កាន់កាប់ប្រើប្រាស់សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។ ទំហំផ្ទៃដីនេះបានបញ្ជាក់ច្បាស់លាស់ ក្នុងគំនូសផែនទីចង្អុលទីតាំងនិងបញ្ជីចំណុចនិយាមកា ដែលចាប់ពីពេលនេះតទៅហៅថា "ទីតាំង" និងមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុភ្ជាប់ជាមួយជាឧបសម្ព័ន្ធ នៃកិច្ចសន្យាកែតម្រូវនេះ។

**ប្រការ២** : ក្នុងអាណត្តិនៃកិច្ចសន្យានេះ បន្ថែមលើខ្លឹមសារនៃប្រការទាំងឡាយដែលមានចែងក្នុងកិច្ចសន្យានេះ ភាគី "ខ" មានកាតព្វកិច្ចដូចខាងក្រោម ៖

២.១- ត្រូវរៀបចំផែនការមេទៅតាមទំហំផ្ទៃដីដែលមានចែងក្នុងប្រការ១ថ្មី យ៉ាងយូររយៈពេល ០៣ (បី) ខែ បន្ទាប់ពីចុះកិច្ចសន្យាកែតម្រូវនេះទៅ។ កម្មវិធីប្រើប្រាស់ដីថ្មីនឹងត្រូវអនុវត្តទៅតាមផែនការមេ ដែលផែនការមេនេះត្រូវមាន៖ កម្មវិធីប្រើប្រាស់ទីតាំង ការប្រើប្រាស់បច្ចេកទេសផ្សេងៗ និងគុណភាពនៃផែនការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍គម្រោងវិនិយោគ។ ភាគី "ខ" អាចចាប់ផ្តើមដំណើរការបានលុះត្រាតែមានការយល់ព្រមលើឯកសារផែនការមេពីភាគី "ក" ជាមុនសិន។

២.២- ដើម្បីឲ្យមានប្រសិទ្ធភាពលើកិច្ចដំណើរការគម្រោងវិនិយោគ ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច និងធានាបានលើការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃ ភាគី "ខ" ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំឲ្យបានច្បាស់លាស់។ ផែនការសកម្មភាពនេះត្រូវបញ្ជូនជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យបានមុន ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃដែលក្រុមហ៊ុនស្នើសុំឈូសឆាយដាំដុះក្នុងអនុតំបន់បន្តបន្ទាប់។

**ប្រការ៣** : **អំពីថិរវេលា**

ត្រូវបានកែសម្រួលប្រការ៤ចាស់ នៃកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ មកជាប្រការ៣ថ្មី ដែលមានខ្លឹមសារដូចខាងក្រោម ៖

៣.១- កិច្ចសន្យានេះមានរយៈពេល៥០ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា នៃកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០។ សេចក្តីជូនដំណឹងស្តីពីការផុតកំណត់រយៈពេលនៃកិច្ចសន្យាត្រូវផ្តល់ជាមុនចំនួន ០១(មួយ) ឆ្នាំ ឬនៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា។

៣.២- ភាគី "ខ" មានសិទ្ធិសុំបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេល៥០ឆ្នាំ រយៈពេល០១ឆ្នាំមុនពេលផុតកំណត់កិច្ចសន្យា ភាគី "ខ" អាចស្នើសុំធ្វើវិនិយោគបន្តទៀត ហើយការបន្តអាចធ្វើទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល តាមរយៈការរបស់ភាគី "ក" ដោយយោងទៅតាមការអនុវត្តកន្លងមករបស់ភាគី "ខ" ការ... នៃទីតាំងសម្បទានដីសេដ្ឋកិច្ច ផលប្រយោជន៍សេដ្ឋកិច្ច សង្គមកិច្ច របស់... និងដោយមានការសិក្សា និងឯកភាពពីភាគី "ក" អំពីល័ក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី។ ក្នុងករណី

មិនមានការសុំបន្តកិច្ចសន្យានេះទេ ភាគី "ក" មានសិទ្ធិផ្តល់កិច្ចសន្យាវិនិយោគជូនទៅភាគីផ្សេងទៀត។

**ប្រការ៤ : ការផ្ទេរ**

ត្រូវបានកែសម្រួលប្រការ១០ចាស់ នៃកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ មកជាប្រការ៤ថ្មី ដែលមានខ្លឹមសារ ដូចខាងក្រោម ៖

ភាគី"ខ" ពុំអាចផ្ទេរកិច្ចសន្យាទៅតតីយបុគ្គលបានឡើយ លើកលែងមានការអនុញ្ញាតតាមច្បាប់ និងបទបញ្ញានានារបស់រាជរដ្ឋាភិបាល។ ប៉ុន្តែភាគី "ខ" អាចសហការទុនវិនិយោគជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលដទៃទៀត ដោយផ្អែកទៅតាមច្បាប់ និងបទបញ្ញាជាធរមាន។ ករណីខាងលើនេះ ភាគី"ខ" ត្រូវសុំការឯកភាពពិនិត្យ និងសម្រេចជាមុនសិនពីភាគី "ក" ។

**ប្រការ៥ : អាសយដ្ឋានសម្រាប់ការជូនដំណឹង**

ត្រូវបានកែសម្រួលប្រការ២០ចាស់ នៃកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ មកជាប្រការ៥ថ្មី ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ភាគី "ក" ៖ រក្សាទុកនៅដដែលដូចកិច្ចសន្យាដើមចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០។
- ភាគី "ខ" ៖

| | | |
|---|---|---|
| ស្នាក់ការកណ្តាល | ៖ | Decastle TK83 ផ្លូវលេខ៣១៥ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ទូរស័ព្ទលេខ | ៖ | (៨៥៥) ២៣ ៩៨៧ ០២៨ |
| ទូរសារលេខ | ៖ | ០២៣ ៩៨៧ ០១៨ |

ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋានជូនដំណឹងខាងលើនេះ ភាគីដែលបានប្តូរអាសយដ្ឋានត្រូវជូនដំណឹងទៅភាគីមួយទៀតឲ្យបានយ៉ាងតិច៣០ (សាមសិប)ថ្ងៃ មុននឹងធ្វើការផ្លាស់ប្តូរ។

**ប្រការ៦ :** ភាគី "ខ" ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងថែរក្សាការពារផ្ទៃដីផ្លូវ អូរ ស្ទឹង និងភ្នំស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនដែលត្រូវបានកាត់ចេញ ដើម្បីរក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

**ប្រការ៧ :** ក្រៅពីប្រការខាងលើ ប្រការផ្សេងៗទៀត នៃកិច្ចសន្យាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ នៅរក្សា និងនៅមានសុពលភាពដដែល។

**ប្រការ៨ :** ភាគីទាំងពីរត្រូវទទួលខុសត្រូវចំពោះការអនុវត្តប្រការទាំងឡាយ ដែលស្ថិតជាធរមាននៃកិច្ចសន្យាចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ និងកិច្ចសន្យាកែសម្រួលថ្មីនេះ ដែលចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ និងបន្តអនុវត្តតាមរាល់គោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧........ខែកញ្ញា........ឆ្នាំ២០១៧

| ភាគី "ក" | ភាគី "ខ" |
|---|---|
| រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមហ៊ុន ឈុន ហុង រ៉ាប់ប៊ើរ បេតធើរ |
| វេង សាខុន | ZHONG WEIKUN |

**កន្លែងតម្កល់ឯកសារ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងយុត្តិធម៌
- សាលាខេត្តក្រចេះ
- រដ្ឋបាលព្រៃឈើ
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ
- ភាគី "ក"
- ភាគី "ខ"
- ឯកសារ កាលប្បវត្តិ